## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ




# របាយការណ៍ស្ថិតិថ្នាក់ក្រោមជាតិ
## ខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ

**រៀបចំដោយៈ**

នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

**រាជធានីភ្នំពេញ ខែ ធ្នូ ឆ្នាំ ២០១៦**

# មាតិកា

ទំព័រ

បុព្វកថា…………………………………………………………………………………..iii

**ជំពូកទី១ សេចក្ដីផ្ដើម**…………………………………………………………………… ១
១.១ សេចក្ដីផ្ដើម……………………………………………………………………… ១
១.២ គោលបំណង……………………………………………………………………… ១
១.៣ វិធីសាស្ត្រប្រមូលទិន្នន័យ…………………………………………………………… ២
១.៤ ការកែច្នៃទិន្នន័យ………………………………………………………………… ២
**ជំពូកទី២ វិភាគទិន្នន័យ**………………………………………………………………… ៣
២.១ ព័ត៌មានប្រជាសាស្ត្រ………………………………………………………………… ៣
២.១.១ ប្រជារាស្ត្រធ្វើការផ្លាស់ប្ដូរទីលំនៅ………………………………………………… ៨
២.១.២ លំនៅដ្ឋាន…………………………………………………………………… ១២
២.១.៣ សម្ភារៈបរិក្ខារដែលទាក់ទងការដឹកជញ្ជូន គ្រឿងម៉ាស៊ីន និងយានយន្ត………… ១៧
២.២ អត្រាកំណើត និងមរណភាព……………………………………………………… ២១
២.២.១ អត្រាកំណើត………………………………………………………………… ២១
២.២.២ មរណភាព…………………………………………………………………… ២២
២.៣ ប្រជារាស្ត្រពិការ…………………………………………………………………… ២៥
២.៣.១ ពិការភាពនៃបុគ្គល…………………………………………………………… ២៥
២.៤ ការប្រើប្រាស់ទឹក និងអនាម័យ……………………………………………………… ២៩
២.៥ បរិស្ថាន និងធនធានធម្មជាតិ……………………………………………………… ៣២
២.៦ គ្រោះធម្មជាតិ……………………………………………………………………… ៣៥
២.៧ សន្តិសុខសង្គម និងសេដ្ឋកិច្ច……………………………………………………… ៣៦
២.៧.១ អសន្តិសុខសង្គម……………………………………………………………… ៣៦
២.៧.២ ស្ថានភាពសេដ្ឋកិច្ចគ្រួសារ……………………………………………………… ៤៣
២.៧.៣ លំហូរវិនិយោគតាមប្រភេទ នៃសកម្មភាពអភិវឌ្ឍន៍……………………………… ៤៨
២.៨ វិស័យអប់រំ និងសេវាសង្គម………………………………………………………… ៤៩
២.៨.១ អសន្តិសុខសង្គម……………………………………………………………… ៤៩
២.៨.១.១ ចំនួនគ្រឹះស្ថានសិក្សា……………………………………………………… ៤៩
២.៨.១.២ ចម្ងាយពីភូមិទៅគ្រឹះស្ថានសិក្សា…………………………………………… ៥២

២.៩ ការស្តាបនាផ្លូវគមនាគមន៍........................................................................... ៥៦
២.១០ ផ្នែកសុខាភិបាល........................................................................... ៥៦
២.១០.១ សេវាកម្មសុខភាព........................................................................... ៥៦
២.១០.២ ប្រេវ៉ាឡង់ជំងឺសំខាន់ៗ........................................................................... ៦០
២.១០.៣ គ្រួសារដែលមានជំងឺអេដស៍ឬផ្ទុកមេរោគអេដស៍ និងកុមារកំព្រា..................... ៦៧
២.១១ កសិកម្ម........................................................................... ៦៩
២.១១.១ គ្រួសារកាន់កាប់តាមទំហំផ្ទៃដី........................................................................... ៦៩
២.១១.២ ផ្ទៃដីដែលបានដាំដុះ និងផ្ទៃដីប្រមូលផល........................................................ ៧១
២.១១.៣ ផ្ទៃដីដាំដំណាំដែលបានស្រោចស្រព........................................................ ៧១
២.១១.៤ ការប្រើប្រាស់ជាតុចូលក្នុងកសិកម្ម........................................................ ៧២
២.១១.៥ ការចិញ្ចឹមបសុសត្វ និងបសុបក្សីរបស់គ្រួសារ............................................ ៧៤
**ជំពូកទី៣ សន្និដ្ឋាន និងអនុសាសន៍**........................................................................... ៧៩
៣.១ សន្និដ្ឋាន........................................................................... ៧៩
៣.២ អនុសាសន៍........................................................................... ៧៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយ នឹងបង្ហាញជូនរបាយការណ៍លទ្ធផលវិភាគស្តីពីស្ថិតិថ្នាក់ក្រោមជាតិជំហានទី១ ដោយផ្អែកលើទិន្នន័យដែលបានប្រមូលពីខេត្ត ៥ គឺខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ។ របាយការណ៍នេះបានប្រមូលនូវទិន្នន័យ សំខាន់ៗរួមមានៈ ស្ថិតិប្រជាសាស្ត្រ កសិកម្ម សេដ្ឋកិច្ច និងស្ថិតិសង្គមកិច្ច សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការរៀបចំផែនការ និងគោលនយោបាយថ្នាក់ក្រោមជាតិ ស្របតាមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។

ខ្ញុំសូមថ្លែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានសម្រេចឲ្យក្រសួងផែនការបង្កើតនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិនេះឡើងតាមអនុក្រឹត្យលេខ៧០អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ កន្លងមក។

សូមថ្លែងអំណរគុណដល់ឯកឧត្តម **សន ស៊ីថន** រដ្ឋលេខាធិការក្រសួងផែនការ លោកជំទាវ **ហាង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានដឹកនាំនិងសម្របសម្រួលការងារតាំងពីចាប់ផ្តើម ដោយមានជំនួយការពីឯកឧត្តម **ម៉េង គីមហ៊ី** អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ ទទួលបន្ទុកនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ លោក **ពេជ ពោធិ** ប្រធាននាយកដ្ឋាន ស្ថិតិថ្នាក់ក្រោមជាតិ លោក លោកស្រី អនុប្រធាននាយកដ្ឋាន លោក លោកស្រី ប្រធាន អនុប្រធានការិយាល័យ ព្រមទាំងមន្ត្រីទាំងអស់ដែលនៅក្នុងនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ។

សូមថ្លែងអំណរគុណដល់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត ប្រធានមន្ទីរផែនការខេត្ត និងសហការីនៃខេត្តទាំង៥ ដូចបានរៀបរាប់ខាងលើ ដែលបានជួយសហការយ៉ាងសកម្មនៅក្នុងអំឡុងពេលចុះប្រមូលទិន្នន័យជាក់ស្តែង។

ខ្ញុំសង្ឃឹមថា អ្នករៀបចំគោលនយោបាយ អ្នកធ្វើផែនការសម្រាប់អភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ អ្នកស្រាវជ្រាវ និងសាធារណៈជនទូទៅ នឹងប្រើប្រាស់របាយការណ៍ដ៏មានសារៈសំខាន់នេះ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ ២០១៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

ឆាយ ថន

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ សេចក្តីផ្តើម

គម្រោងគាំទ្រស្ថិតិថ្នាក់ក្រោមជាតិ គឺជាគម្រោងមួយថ្មីដែលវិទ្យាស្ថានជាតិស្ថិតិបានរៀបចំដើម្បីប្រមូលទិន្នន័យស្ថិតិថ្នាក់មូលដ្ឋាន និងធ្វើការវិភាគលើលទ្ធផលទាំងនោះ ស្របតាមការធ្វើវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់ថ្នាក់ក្រោមជាតិ ។

ស្ថិតិដែលត្រូវប្រមូលពីថ្នាក់មូលដ្ឋាន គឺរួមមានស្ថិតិប្រជាសាស្ត្រ ស្ថិតិកសិកម្ម ស្ថិតិសេដ្ឋកិច្ច និងស្ថិតិសង្គមកិច្ច ដែលត្រូវយកមកចងក្រងវិភាគ។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជាអ្នកអនុវត្តគម្រោងនេះផ្ទាល់ដែលស្របតាមភារកិច្ចរបស់នាយកដ្ឋាន និងតាមសេចក្តីសម្រេចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ស្នើឲ្យបង្កើតនាយកដ្ឋាននេះឡើងតាម អនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ។




ប្រទេសកម្ពុជាបានបែងចែកជា ៤ តំបន់គឺ តំបន់ទំនាប តំបន់បឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ និងតំបន់ខ្ពង់រាបនិងភ្នំ ។ ជំហានទី១ ត្រូវបានអនុវត្តទៅលើខេត្តចំនួន ៥ គឺ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និង កំពង់ស្ពឺ សម្រាប់ឆ្នាំ ២០១៦ ជាខេត្តនៅក្នុងចំណោមរាជធានីខេត្តទាំង ២៥របស់ប្រទេសកម្ពុជាដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៥ ពីរាជធានីភ្នំពេញ ទៅខេត្តបន្ទាយមានជ័យ។ ដោយឡែកខេត្ត កំពង់ស្ពឺមួយផ្នែកធំជាប់នឹងផ្លូវជាតិលេខ៤ ផងដែរ។

## ១.២ គោលបំណង

គោលបំណងសំខាន់នៃគម្រោងស្ថិតិថ្នាក់ក្រោមជាតិ គឺវិភាគទិន្នន័យរកឲ្យឃើញនូវបញ្ហាដែលអាចកើតមានឡើងនៅក្នុងមូលដ្ឋាន ដែលមានទិន្នន័យដែលទាក់ទងទៅ ព័ត៌មានប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ និងកសិកម្ម របស់ខេត្តទាំងប្រាំ។

## ១.៣ វិធីស្រាស្តប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យគឺធ្វើឡើយដោយមន្ត្រីនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងមានការចូលរួមពីមន្ត្រីមន្ទីរផែនការខេត្តទាំងប្រាំ ដោយប្រើប្រាស់កម្រសំណួរស្ថិតិថ្នាក់ក្រោមជាតិ ចុះសម្ភាសន៍ផ្ទាល់ជាមួយប្រធានភូមិ គ្រប់ភូមិទាំងអស់ក្នុងខេត្តទាំងប្រាំ ដែលមានរយៈពេល ១៥ថ្ងៃ គឺចាប់ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ២០ ខែ មិនា ឆ្នាំ២០១៦។ កាលបរិច្ឆេទយោងគឺរយៈ១២ខែកន្លងមក ចាប់ពី ខែ មិនា ឆ្នាំ២០១៥ ដល់ខែ មិនា ឆ្នាំ២០១៦។

## ២.៤ ការកែច្នៃទិន្នន័យ

ទិន្នន័យនេះ គឺត្រូវបានធ្វើការកែកំហុស និងវាយបញ្ចូលនៅក្នុងកុំព្យូទ័រដោយប្រើប្រាស់កម្មវិធី Excel, SPSS និង CSPro សម្រាប់ធ្វើជាតារាង និងវិភាគទិន្នន័យទាំងនេះ ។ ចំពោះការវាយអត្ថបទកម្មវិធី Microsoft Word ត្រូវបានយកមកប្រើប្រាស់ផងដែរ។ ការវាយបញ្ចូលទិន្នន័យ និងវិភាគទិន្នន័យមានរយៈពេល ០២ ខែ គឺចាប់ពីថ្ងៃទី ០១ ខែមេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦ បន្ទាប់ពីការចុះសម្ភាសន៍ ស្រង់ទិន្នន័យតាមមូលដ្ឋានរួចរាល់។

# ជំពូក ២
# វិភាគទិន្នន័យ

នៅក្នុងរបាយការណ៍នេះ មានទិន្នន័យដែលទាក់ទងទៅ នឹងព័ត៌មានប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ និងកសិកម្ម។

## ២.១ ព័ត៌មានប្រជាសាស្ត្រ

ចំនួនគ្រួសារ និងប្រជាពលរដ្ឋនៅក្នុងខេត្តទាំង៥ (គិតត្រឹមថ្ងៃទី ០៣ ខែ មិនា ឆ្នាំ២០១៦) រួមមាន ៖ ខេត្តបន្ទាយមានជ័យមានចំនួន ១៨១២៦១ គ្រួសារ និងសរុបចំនួនប្រជាពលរដ្ឋ ៧៣៣៦០០ នាក់ បាត់ដំបងចំនួន ២៥០៩៨០ គ្រួសារ និងសរុបចំនួនប្រជាពលរដ្ឋ ១១៣២៧៩៤ កំពង់ឆ្នាំងចំនួន ១២៤២០៩ គ្រួសារ និងសរុបចំនួនប្រជាពលរដ្ឋ ៥៤៥៣៥១ នាក់ កំពង់ស្ពឺចំនួន ១៧៦២១១ គ្រួសារ និងសរុបចំនួនប្រជាពលរដ្ឋ ៨៤២៤៧៦ នាក់ និងពោធិ៍សាត់ចំនួន ១០៨៦៤៣ គ្រួសារ និងសរុបចំនួនប្រជាពលរដ្ឋ ៤៧៣៥៩៤នាក់ តារាង (១)។

*តារាង (១) ចំនួនប្រជាជន និងគ្រួសារ*

| ចំនួនសរុប | បន្ទាយមានជ័យ | បាត់ដំបង | កំពង់ឆ្នាំង | កំពង់ស្ពឺ | ពោធិ៍សាត់ |
|---|---|---|---|---|---|
| គ្រួសារ | ១៨១.២៦១ | ២៥០.៩៨០ | ១២៤.២០៩ | ១៧៦.២១១ | ១០៨.៦៤៣ |
| ប្រជាជន | ៧.៣៣.៦០០ | ១.១៣២.៧៩៤ | ៥៤៥.៣៥១ | ៨៤២.៤៧៦ | ៤៧៣.៥៩៤ |




រូប(១)បានបង្ហាញថា៖ ខេត្តបន្ទាយមានជ័យក្នុងចំណោមមេគ្រួសារសរុប (១៨១២៦១) មានមេគ្រួសារជាស្ត្រី ១១% និងមានគ្រួសារដែលស្ត្រីជាមេគ្រួសារមានកូនអាយុក្រោម៥ឆ្នាំ ១% ខេត្តបាត់ដំបងចំណោមមេគ្រួសារសរុប (២៥០៩៨០) ក្នុងនោះមានមេគ្រួសារជាស្ត្រី ១៤% និងមានគ្រួសារដែលស្ត្រីជាមេគ្រួសារមានកូនអាយុក្រោម៥ឆ្នាំ ២% ខេត្តកំពង់ឆ្នាំងចំណោមមេគ្រួសារសរុប (១២៤២០៩) ក្នុងនោះមានមេគ្រួសារជាស្ត្រី ១៨% និងមានគ្រួសារដែលស្ត្រីជាមេគ្រួសារមានកូនអាយុក្រោម៥ឆ្នាំ ១% ខេត្តកំពង់ស្ពឺ ក្នុងចំណោមមេគ្រួសារសរុប(១៧៦២១១) ក្នុងនោះមានមេគ្រួសារជាស្ត្រី ១៦% និងមានគ្រួសារដែលស្ត្រីជាមេគ្រួសារមានកូនអាយុក្រោម៥ឆ្នាំ ៣% និងខេត្តពោធិ៍សាត់ចំណោមមេគ្រួសារសរុប (១០៨៦៤៣) ក្នុងនោះមានមេគ្រួសារជាស្ត្រី ១៨% និងមានគ្រួសារដែលស្ត្រីជាមេគ្រួសារមានកូនអាយុក្រោម៥ឆ្នាំ ៣% ។

## *ក. គ្រួសារតាមជនជាតិ*




រូប (២) ភាគរយគ្រួសារតាមជនជាតិ និងតាមខេត្ត

រូប(៣)បានបង្ហាញថា៖ ចំណោមគ្រួសារសរុបគ្រប់ខេត្ត (ក្នុងនោះមិនរាប់បញ្ចូលភាគរយគ្រួសារដែលជាជនជាតិខ្មែរ យកតែជនជាតិមានភាគរយបីលំដាប់ប៉ុណ្ណោះ) **ខេត្តបន្ទាយមានជ័យ** ក្នុងចំណោមគ្រួសារសរុប (១៨១២៦១) គ្រួសារដែលមានភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិខ្មែរអ៊ីស្លាម ០.៣៦% ជនជាតិឡាវ ០.១២% និងគ្រួសារជាជនវៀតណាម ០.០១% **ខេត្តបាត់ដំបង** ចំណោមមេគ្រួសារសរុប (២៥០៩៨០) ក្នុងនោះមានគ្រួសារដែលភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិខ្មែរអ៊ីស្លាម ១.១៥% ជនជាតិវៀតណាម ០.១៥% និងគ្រួសារជាជនជាតិបរទេសផ្សេងទៀត ០.០២% **ខេត្តកំពង់ឆ្នាំង** ចំណោមមេគ្រួសារសរុប (១២៤២០៩) ក្នុងនោះមានគ្រួសារដែលភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិខ្មែរអ៊ីស្លាម ៥.៣០% ជនជាតិវៀតណាម ០.៣១% និងគ្រួសារជាជនជាតិបរទេសផ្សេងទៀត ០.០២% **ខេត្តកំពង់ស្ពឺ** ក្នុងចំណោមមេគ្រួសារសរុប (១៧៦២១១) ក្នុងនោះមានគ្រួសារដែលភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺជនជាតិភាគតិច ០.២១% ខ្មែរអ៊ីស្លាម ០.០៥% និងគ្រួសារជាជនជនជាតិវៀតណាម ០.០២% និង**ខេត្តពោធិ៍សាត់** ចំណោមមេគ្រួសារសរុប (១០៨៦៤៣) ក្នុងនោះ

មានគ្រួសារដែលភាគរយខ្ពស់បន្ទាប់ពីជនជាតិខ្មែរគឺ ជនជាតិខ្មែរអ៊ីស្លាម ៣.៤៧% ជនជាតិវៀតណាម ១.១៨% និងគ្រួសារជាជនជាតិភាគតិច ០.៥២% ។

## ខ. ស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារ

រូប (៣) ភាគរយនៃមេគ្រួសារដែលរស់នៅផ្សេងគ្នា និងមេម៉ាយ ឬពោះម៉ាយតាមខេត្ត




រូប (៣) បានបង្ហាញថា៖ ស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារចំណោមគ្រួសារសរុបគ្រប់ខេត្ត (ក្នុងនោះមិនរាប់បញ្ចូលភាគរយមេគ្រួសារដែលបានរៀបការនិងរស់នៅជាមួយគ្នាទេ) **ខេត្តបន្ទាយមានជ័យ** ចំណោមមេគ្រួសារសរុប (១៨១២៦១) ក្នុងនោះមានមេគ្រួសារដែលជាមេម៉ាយ/ពោះម៉ាយមាន ១០.៤% និងមេគ្រួសារដែលរស់នៅផ្សេងគ្នា ០.៥% **ខេត្តបាត់ដំបង** ចំណោមមេគ្រួសារសរុប (២៥០៩៨០) ក្នុងនោះមានមេគ្រួសារដែលជាមេម៉ាយ/ពោះម៉ាយមាន ១២.៨% និងមេគ្រួសារដែលរស់នៅផ្សេងគ្នា ១.៨% **ខេត្តកំពង់ឆ្នាំង** ចំណោមមេគ្រួសារសរុប (១២៤២០៩) ក្នុងនោះមានមេគ្រួសារដែលជាមេម៉ាយ/ពោះម៉ាយមាន ១៥.៤% និងមេគ្រួសារដែលរស់នៅផ្សេងគ្នា ០.៤% **ខេត្តកំពង់ស្ពឺ** ក្នុងចំណោមមេគ្រួសារសរុប(១៧៦២១១) ក្នុងនោះមានមេគ្រួសារដែលជាមេម៉ាយ/ពោះម៉ាយមាន១០.៣% និងមេគ្រួសារដែលរស់នៅផ្សេងគ្នា០.៤% និង**ខេត្តពោធិ៍សាត់** ចំណោមមេគ្រួសារសរុប (១០៨៦៤៣) ក្នុងនោះមានមេគ្រួសារដែលជាមេម៉ាយ/ពោះម៉ាយមាន១៣.៨%និងមេគ្រួសារដែលរស់នៅផ្សេងគ្នា១.៧% ។

## *គ. ស្ថានភាពលែងលះតាមមុខរបរនៃការងារ*

រូប (៤) ភាគរយមេគ្រួសារលែងលះតាមមុខរបរ នៃការងារ




រូប (៤) បានបង្ហាញថា៖ ស្ថានភាពការលែងលះ និងរស់នៅផ្សេងគ្នាតាមវិជ្ជាជីវៈ ក្នុងចំណោមគ្រួសារសរុបគ្រប់ខេត្ត ខេត្តបន្ទាយមានជ័យ ភាពលែងលះខ្ពស់ជាងគេលើការងារជាពលករ ៣% អ្នកមានវិជ្ជាជីវៈ និងអ្នកនយោបាយ ប្រហែល ២% មន្ត្រីរាជការ ១% ខេត្តបាត់ដំបងភាពលែងលះខ្ពស់ជាងគេលើអ្នកមានវិជ្ជាជីវៈ ៥% បន្ទាប់មក ពលករប្រហែល ៥% ដែរ និងអ្នកនយោបាយ ប្រហែល ២% មន្ត្រីរាជការ ១% ខេត្តកំពង់ឆ្នាំងភាពលែងលះខ្ពស់ជាងគេលើអ្នកមានវិជ្ជាជីវៈ ៨% បន្ទាប់មក មន្ត្រីរាជការ ៤% និងអ្នកនយោបាយនិងពលករ ៤% ខេត្តកំពង់ស្ពឺភាពលែងលះប្រហែល ៣% គ្រប់ជំនាញ លើកលែងតែអ្នកមានវិជ្ជាជីវៈ ២% និងខេត្តពោធិ៍សាត់ភាពលែងលះខ្ពស់ជាងគេលើ ពលករ ៧% អ្នកនយោបាយ ៥% អ្នកជំនួញ ៣% អ្នកមានវិជ្ជាជីវៈ និង មន្ត្រីរាជការ ១% ។

### *២.១.២ ប្រជាពលរដ្ឋធ្វើការផ្លាស់ប្ដូរទីលំនៅ*

### *ក. ការធ្វើចំណាកស្រុក និងចំណូលស្រុក*




រូប (៥) គ្រួសារធ្វើចំណាកស្រុក និងចំណូលស្រុកតាមខេត្ត

រូប (៥) បានបង្ហាញថា ៖ ស្ថានភាពការធ្វើអន្តោប្រវេសន៍របស់គ្រួសារចំណោមគ្រួសារសរុបគ្រប់ខេត្ត រួមមាន ៖ ខេត្តបន្ទាយមានជ័យ ចំណោមគ្រួសារសរុប (១៨១២៦១) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុកស្មើ ៧៩៦៧ គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកស្មើនឹង ១៧៧៦ គ្រួសារ ខេត្តបាត់ដំបង ចំណោមគ្រួសារសរុប (២៥០៩៨០) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុកស្មើ ៥៨៩២ គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកស្មើនឹង ១៨១៦ គ្រួសារ ខេត្តកំពង់ឆ្នាំង ចំណោមគ្រួសារសរុប (១២៤២០៩) មានគ្រួសារធ្វើចំណាកស្រុកស្មើ ៩៦៩ គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកស្មើនឹង ៤៨៣ គ្រួសារ ខេត្តកំពង់ស្ពឺ ក្នុងចំណោមគ្រួសារសរុប (១៧៦២១១) ក្នុងនោះមានមានគ្រួសារធ្វើចំណាកស្រុកស្មើ ៥២០៧ គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកស្មើនឹង ១៥៩៨ គ្រួសារ និង ខេត្តពោធិ៍សាត់ក្នុងចំណោមគ្រួសារសរុប (១០៨៦៤៣) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុកស្មើ ៨១៥១ គ្រួសារ និងគ្រួសារធ្វើចំណូលស្រុកស្មើនឹង ១០៩៨ គ្រួសារ។ សរុបសេចក្ដីមកការធ្វើចំណាកស្រុករបស់គ្រួសារខ្ពស់គឺខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ បន្ទាប់មកខេត្តបាត់ដំបង និងខេត្តកំពង់ស្ពឺ។

## ខ. គ្រួសារធ្វើចំណាកស្រុក ក្នុងនិងក្រៅប្រទេស

រូប (៦) ចំនួនគ្រួសាររកការងារធ្វើក្នុងប្រទេស និងក្រៅប្រទេសតាមខេត្ត




រូប (៦) បានបង្ហាញថា៖ ស្ថានភាពការធ្វើចំណាកស្រុករបស់គ្រួសារក្នុងចំណោមគ្រួសារសរុបគ្រប់ខេត្តរួមមាន៖ ខេត្តបន្ទាយមានជ័យ មានគ្រួសារសរុប(១៨១២៦១) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុករកការងារក្រៅប្រទេសស្មើ ៤៤០ គ្រួសារ និងមានគ្រួសារធ្វើចំណាកស្រុករកការងារក្នុងប្រទេសស្មើនឹង ៥៤ គ្រួសារ **ខេត្តបាត់ដំបង** ចំណោមគ្រួសារសរុប (២៥០៩៨០) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុករកការងារក្រៅប្រទេសស្មើ ២២២០៨ គ្រួសារ និងមានគ្រួសារធ្វើចំណាកស្រុករកការងារក្នុងប្រទេសស្មើនឹង ៨៩៤៩ គ្រួសារ **ខេត្តកំពង់ឆ្នាំង** ចំណោមគ្រួសារសរុប (១២៤២០៩) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុករកការងារក្រៅប្រទេសស្មើ ៤០១ គ្រួសារ និងមានគ្រួសារធ្វើចំណាកស្រុករកការងារក្នុងប្រទេសស្មើនឹង ៩៨៥ គ្រួសារ **ខេត្តកំពង់ស្ពឺ** ក្នុងចំណោមគ្រួសារសរុប (១៧៦២១១) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុករកការងារក្រៅប្រទេសស្មើ ៣៧៩ គ្រួសារ និងមានគ្រួសារធ្វើចំណាកស្រុករកការងារក្នុងប្រទេសស្មើនឹង ២៣៣៥ គ្រួសារ និង**ខេត្តពោធិ៍សាត់** ក្នុងចំណោមគ្រួសារសរុប (១០៨៦៤៣) ក្នុងនោះមានគ្រួសារធ្វើចំណាកស្រុករកការងារក្រៅប្រទេសស្មើ ៣១០០ គ្រួសារ និងមានគ្រួសារធ្វើចំណាកស្រុករកការងារក្នុងប្រទេសស្មើនឹង ៤៤៧០ គ្រួសារ។

### *គ. ពលករចំណាកស្រុកក្នុងនិងក្រៅប្រទេស*

*តារាង (២) ចំនួនអ្នកធ្វើចំណាកស្រុកក្នុង និងក្រៅប្រទេសតាមខេត្ត*

| ពលករចំណាកស្រុក | បន្ទាយមានជ័យ | បាត់ដំបង | កំពង់ឆ្នាំង | កំពង់ស្ពឺ | ពោធិ៍សាត់ |
|---|---|---|---|---|---|
| នៅក្នុងប្រទេស | ៦៧.២៤០ | ៤៥.៥៩៦ | ២៥.៧១៥ | ២៩.១៤៤ | ២០.១៣៨ |
| នៅក្រៅប្រទេស | ៥.១៩៦ | ៩៨.២៩៥ | ៩.៤៨១ | ៧.៩៥៨ | ១៥.៤២២ |
| សរុប | ៧២.៤៣៦ | ១៤៣.៨៩១ | ៣៥.១៩៦ | ៣៧.១០២ | ៣៥.៥៦០ |

តារាង (២) បានបង្ហាញថា៖ ស្ថានភាពពលករចំណាកស្រុកក្នុង និងក្រៅប្រទេសរួមមាន៖ ខេត្តបន្ទាយមានជ័យ ចំណោមពលករសរុប (៧២៤៣៦) ក្នុងនោះមានពលករការងារក្រៅប្រទេសស្មើ ៥១៩៦ នាក់ និងពលករការងារក្នុងប្រទេសស្មើនឹង ៦៧២៤០នាក់ **ខេត្តបាត់ដំបង** ចំណោមពលករសរុប (១៤៣៨៩១នាក់) ក្នុងនោះមានពលករការងារក្រៅប្រទេសស្មើ ៩៨២៩៥ នាក់ និងពលករការងារក្នុងប្រទេសស្មើនឹង ៤៥៥៩៦ នាក់ **ខេត្តកំពង់ឆ្នាំង** ចំណោមពលករសរុប (៣៥១៩៦) ក្នុងនោះមានពលករការងារក្រៅប្រទេសស្មើ ៩៤៨១ នាក់ និងពលករការងារក្នុងប្រទេសស្មើនឹង ២៥៧១៥ នាក់ **ខេត្តកំពង់ស្ពឺ** ចំណោមពលករសរុប (៣៧១០២) ក្នុងនោះមានពលករការងារក្រៅប្រទេសស្មើ ៧៩៥៨ នាក់ និងពលករការងារក្នុងប្រទេសស្មើនឹង ២៩១៤៤ នាក់ និង**ខេត្តពោធិ៍សាត់** ចំណោមពលករសរុប (៣៥៥៦០) ក្នុងនោះមានពលករការងារក្រៅប្រទេស ស្មើ ១៥៤២២ នាក់ និងពលករការងារក្នុងប្រទេសស្មើនឹង ២០១៣៨ នាក់ ។

## ឃ. ពលករស្វែងរកការងារក្នុង និងក្រៅប្រទេសបែងចែកតាមភេទ

### ១. ក្នុងប្រទេស




រូប(៧) បានបង្ហាញថា៖ ស្ថានភាពពលករចំណាកស្រុករកការងារក្នុងប្រទេស របស់ខេត្តបន្ទាយមានជ័យ ចំណោមពលករសរុប (៦៧២៤០នាក់) ក្នុងនោះមានភាគរយពលការីនី ស្មើ ៤៥% ខេត្តបាត់ដំបង ចំណោមពលករសរុប (៤៥៥៩៦នាក់) មានភាគរយពលការីនី ស្មើ៤៤% ខេត្តកំពង់ឆ្នាំង ចំណោមពលករសរុប (២៥៧១៥នាក់) មានភាគរយពលការីនី ស្មើ ៥៩% ខេត្តកំពង់ស្ពឺ ចំណោមពលករសរុប (២៩១១៤នាក់) មានភាគរយពលការីនី ស្មើ ៥៦% និងខេត្តពោធិ៍សាត់ ចំណោមពលករសរុប (២០១៣៨នាក់) មានភាគរយពលការីនី ស្មើ ៥៣% ។

### ២. ក្រៅប្រទេស



រូប(៨) បានបង្ហាញថា៖ ស្ថានភាពពលករចំណាកស្រុករកការងារក្រៅប្រទេស របស់ខេត្តបន្ទាយមានជ័យ ចំណោមពលករសរុប (៥១៩៦នាក់) ក្នុងនោះមានភាគរយពលការីនី ស្មើ ៤៩% ខេត្តបាត់ដំបង ចំណោមពលករសរុប (៩៨២៩៥នាក់) មានភាគរយពលការីនី ស្មើ ៤៤% ខេត្តកំពង់ឆ្នាំង ចំណោម ពលករសរុប (៩៤៨១នាក់) មានភាគរយពលការីនី ស្មើ ៣៧% ខេត្តកំពង់ស្ពឺ ចំណោមពលករសរុប (៧៩៥៨នាក់) មានភាគរយពលការីនី ស្មើ ៣៦% និងខេត្តពោធិ៍សាត់ ចំណោមពលករសរុប (១៥៤២២នាក់) មានភាគរយពលការីនី ស្មើ ៤៣% ។

## ២.១.៣ លំនៅដ្ឋាន

### *ក. ប្រភេទនៃដំបូលផ្ទះរបស់គ្រួសារ*

*តារាង(៣) ប្រភេទនៃដំបូលផ្ទះ*

| ប្រភេទនៃដំបូលផ្ទះ | បន្ទាយមានជ័យ | | បាត់ដំបង | | កំពង់ឆ្នាំង | | កំពង់ស្ពឺ | | ពោធិ៍សាត់ | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| បេតុង | ៩.១៨១ | ៦ | ១៣.១៥៥ | ៥ | ២.១២៩ | ២ | ៤២.២៨៣ | ២ | ១.៣៥១ | ១ |
| ក្បឿង | ៨.៧៣០ | ៦ | ២០.០៧៧ | ៨ | ៣៩.២៧៣ | ៣១ | ៧៤.៣៨០ | ៤៣ | ២៧.០១៩ | ២៧ |
| ស័ង្កសី / ហ្វីប្រូ | ១៣០.០៤១ | ៨៤ | ១៩០.៥៧៧ | ៧៩ | ៥៨.៨៩៣ | ៥៣ | ៨៣.៧៧៨ | ៤៨ | ៥៩.៥៧៧ | ៥៩ |
| ប្រក់ស្លឹក | ៣.៣៧២ | ២ | ១៣.៧៦០ | ៦ | ១៥.៤៣៣ | ១៤ | ៨.៤៩៣ | ៥ | ១២.២១១ | ១២ |
| ផ្សេងទៀត | ៣.៥៣៩ | ២ | ២.៧៨៤ | ១ | ៩៥៩ | ១ | ២.១៩៣ | ១ | ១.៥៦៧ | ២ |
| សរុប | **១៥៤.៨៦៣** | ១០០ | **២៤០.៣៥៣** | ១០០ | **១១.១៦៨៧** | ១០០ | **១៧៣.១២៧** | ១០០ | **១០១.៧២៥** | ១០០ |

តារាង (៣) បានបង្ហាញភាគរយខ្ពស់នៃដំបូលផ្ទះរបស់ប្រជាពលរដ្ឋតាមបណ្តាខេត្តទាំង៥ គឺដំបូលប្រក់អំពីស័ង្កសី/ហ្វីប្រូ ដែលខេត្តបន្ទាយមានជ័យ ៨៤% ខេត្តបាត់ដំបង ៧៩% ខេត្តកំពង់ឆ្នាំង ៥៣% ខេត្តកំពង់ស្ពឺ ៤៨% និងខេត្តពោធិ៍សាត់ ៥៩%។ រីឯដំបូលប្រក់អំពីស្លឹកវិញមានភាគរយទាបចំពោះ ខេត្តបន្ទាយមានជ័យមានតែ ២% ទន្ទឹមនឹងនោះដំបូលប្រក់អំពីស្លឹកមានភាគរយខ្ពស់នៅ ខេត្តកំពង់ឆ្នាំង ១៤% និងខេត្តពោធិ៍សាត់ ១២%។

## ខ. ការប្រើប្រាស់អគ្គិសនីតាមប្រភេទនៃដំបូលផ្ទះ




រូប (៩) បានបង្ហាញថា៖ ស្ថានភាពការប្រើប្រាស់អគ្គិសនីគ្រប់ខេត្តទាំងប្រាំរបស់គ្រួសារដំបូលប្រក់អំពីបេតុងជាង ៩០% បន្ទាប់មកគ្រួសារដំបូលប្រក់អំពីក្បឿង និងស័ង្កសី/ហ្វីប្រូ ក៏ខ្ពស់ជាង ៥០% ដែរសូម្បីតែគ្រួសារដំបូលប្រក់អំពីស្លឹកក៏មានអគ្គិសនីប្រើប្រាស់ជាង ២០% ដែរនេះសបញ្ជាក់ឲ្យឃើញថាវិស័យអគ្គិសនីមានការអភិវឌ្ឍជាលំដាប់។

## *គ. គ្រួសារដែលមា នទូរទស្សន៍ប្រើប្រាស់ចែកតាមប្រភេទនៃដំបូលផ្ទះ*




រូប( ១០ )បានបង្ហាញថាៈស្ថានភាពការប្រើប្រាស់ទូរទស្សន៍ស្របជាមួយនឹងការប្រើប្រាស់អគ្គិសនីដែរស្ទើរគ្រប់ខេត្តទាំងប្រាំ របស់គ្រួសារមានដំបូលផ្ទះធ្វើអំពីបេតុងជាង ៩០% បន្ទាប់មកគ្រួសារមានដំបូលផ្ទះប្រក់ក្បឿង និងស័ង្កសី/ហ្វីប្រូ ក៏ខ្ពស់ជាង ៧០% ដែរសូម្បីតែគ្រួសារមានដំបូលប្រក់ស្លឹក ក៏មានទូរទស្សន៍ប្រើប្រាស់ជាង ៥០% ដែរ នេះសរបញ្ជាក់ឲ្យឃើញថាវិស័យអគ្គិសនីមានការអភិវឌ្ឍនាំឲ្យមានការប្រើប្រាស់ឧបករណ៍ប្រើអគ្គិសនីច្រើនផងដែរ។

## ឃ. គ្រួសារដែលមានកុំព្យូទ័រប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ

រូប (១១) ភាគរយនៃគ្រួសារមានកុំព្យូទ័រប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ និងតាមខេត្ត




រូប (១១) បានបង្ហាញថា៖ ស្ថានភាពគ្រួសារដែលមានកុំព្យូទ័រប្រើប្រាស់ ស្រដៀងគ្នាជាមួយនឹងគ្រួសារមានអគ្គិសនីប្រើប្រាស់ផងដែរស្ទើរគ្រប់ខេត្តទាំងប្រាំ។ ប៉ុន្តែគ្រួសារដែលមានកុំព្យូទ័រប្រើប្រាស់ភាគច្រើនចំពោះតែគ្រួសារដែលមានដំបូលធ្វើអំពីបេតុង (១១% នៅខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ១២% ពោធិ៍សាត់ ១២% បន្ទាយមានជ័យ ៨% បាត់ដំបង ៧%) បន្ទាប់មកគ្រួសារដំបូលប្រក់អំពីក្បឿងមានកុំព្យូទ័រប្រើប្រាស់ (១% នៅខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ១% ពោធិ៍សាត់ ១% បន្ទាយមានជ័យ ៣% និងខេត្តបាត់ដំបង ៣%)។

## ង. គ្រួសារដែលមានទូរស័ព្ទដៃប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ

រូប (១២) ភាគរយនៃគ្រួសារមានទូរស័ព្ទប្រើប្រាស់តាមប្រភេទនៃដំបូលផ្ទះ និងតាមខេត្ត




រូប (១២) បានបង្ហាញថាមានភាគរយខ្ពស់នៅគ្រប់គ្រួសារនៃប្រភេទដំបូលផ្ទះរបស់ប្រជាពលរដ្ឋតាមបណ្តាខេត្តទាំងប្រាំ សូម្បីតែគ្រួសារ**ដំបូលប្រក់អំពីស្លឹក** ក៏មានភាគរយខ្ពស់ដែរ (ខេត្តបន្ទាយមានជ័យ ៨២% ខេត្តបាត់ដំបង ៧៦% ខេត្តកំពង់ឆ្នាំង ៨០% ខេត្តកំពង់ស្ពឺ ៦៣% និងខេត្តពោធិ៍សាត់ ៨៣%)។ ចំណែកគ្រួសារដែលមានដំបូលប្រក់ក្បឿង និងស័ង្កសី/ហ្វីប្រូ វិញ គឺមានកាន់តែខ្ពស់ទៅទៀត (ចន្លោះពី ៩៣ ទៅ ១០៥%) ចំពោះគ្រួសារនៃប្រភេទដំបូលបេតុងគឺមានលើសពី ១០០% លើកលែងតែខេត្តបាត់ដំបងមានត្រឹមតែ ៩២% ចំពោះការប្រើប្រាស់ទូរស័ព្ទ។ នេះបញ្ជាក់ឲ្យឃើញថាវិស័យសេវាទូរគមនាគមន៍មានការរីកចម្រើន មានអ្នកវិនិយោគច្រើននៅក្នុងវិស័យនេះ។

## *២.១.៥ សម្ភារៈ បរិក្ខារដែលទាក់ទងការដឹកជញ្ជូនគ្រឿងម៉ាស៊ីន និងយានយន្ត*

*តារាង (៤) ប្រភេទបរិក្ខារតាមប្រភេទ និងតាមខេត្ត*

| ប្រភេទនៃបរិក្ខារ | បន្ទាយមានជ័យ | | បាត់ដំបង | | កំពង់ឆ្នាំង | | កំពង់ស្ពឺ | | ពោធិ៍សាត់ | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| កសិកម្មនិងនេសាទ | ៧៥.៧៦៦ | ៣៩.៦ | ៥៥.២២០ | ២៣.៨ | ៥៦.៦៦០ | ៣៦.៧ | ៤៨.៧២៣ | ២១.៦ | ២៦.២៣៧ | ២៥.១ |
| សេវាដឹកជញ្ជូន | ៣.៤៧៨ | ១.៨ | ៤.៦៣៨ | ២.០ | ២.៧៦៤ | ១.៨ | ៦.៦៦៥ | ២.៩ | ១.៦៥៦ | ១.៦ |
| សេវាដឹកជញ្ជូន និងប្រើប្រាស់ផ្ទាល់ខ្លួន | ១១២.២៥២ | ៥៨.៦ | ១៧១.៨៣៥ | ៧៤.២ | ៩៤.៧៨៤ | ៦១.៥ | ១៧០.៦៣៦ | ៧៥.៥ | ៧៦.៤៤៣ | ៧៣.៣ |
| សរុប | **១៩១.៤៩៦** | **១០០** | **២៣១.៦៩៣** | **១០០** | **១៥៤.២០៨** | **១០០** | **២២៦.០២៤** | **១០០** | **១០៤.៣៣៦** | ១០០ |

តារាង (៤) បានបង្ហាញថាភាគរយនៃប្រភេទបរិក្ខាររបស់ប្រជាពលរដ្ឋដែលមាន តាមបណ្តាខេត្តទាំងប្រាំ លើគ្រឿងម៉ាស៊ីនបរិក្ខារសម្រាប់កសិកម្ម និងនេសាទ ខេត្តបន្ទាយមានជ័យមានប្រមាណ ៤០% ខេត្តបាត់ដំបងមានប្រមាណ ២៤% ខេត្តកំពង់ឆ្នាំងមានប្រមាណ ៣៧% ខេត្តកំពង់ស្ពឺមានប្រមាណ ២២% និងខេត្តពោធិ៍សាត់ ២៥%។ ចំណែកសេវាដឹកជញ្ជូន និងប្រើប្រាស់ផ្ទាល់ខ្លួនវិញមានភាគរយខ្ពស់ ខេត្តបាត់ដំបង កំពង់ស្ពឺ និងខេត្តពោធិ៍សាត់ ( ៧៤.២% ៧៥.៥% និង៧៣.៣%) ចំពោះខេត្តបន្ទាយមានជ័យមាន ៥៨.៦% និងខេត្តកំពង់ឆ្នាំង ៦១.៥%។

## *ក. ប្រភេទនៃបរិក្ខារសម្រាប់កសិកម្ម និងនេសាទ*




រូប (១៣) បានបង្ហាញថា៖ ចំនួនប្រភេទនៃបរិក្ខារកសិកម្មនិងនេសាទរបស់ខេត្តបន្ទាយមានជ័យសរុប(៣៤៧៨គ្រឿង ស្មើ ១.៨% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះឧបករណ៍កសិកម្ម និងគ្រឿងម៉ាស៊ីន ម៉ាស៊ីនភ្ជួររាស់ ៥១% ឧបករណ៍កសិកម្មផ្សេង ៤៧% ម៉ាស៊ីនច្រូតកាត់និងទូកនេសាទ ១% ដូចគ្នា ខេត្តបាត់ដំបង (៥៥២២០គ្រឿង ស្មើ ២៣.៨% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ឧបករណ៍កសិកម្មនិងគ្រឿងម៉ាស៊ីនភ្ជួររាស់ ៨១% ឧបករណ៍កសិកម្មផ្សេងទៀតមាន ៣១% ទូកនេសាទ ១៣% និងម៉ាស៊ីនច្រូតកាត់ ២% ខេត្តកំពង់ឆ្នាំង (៥៦៦៦០គ្រឿង ស្មើ ៣៦.៧% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត)ឧបករណ៍កសិកម្មនិងគ្រឿងម៉ាស៊ីនភ្ជួររាស់ ៤៤% ឧបករណ៍កសិកម្មផ្សេងទៀតមាន ៣១% ទូកនេសាទ ២៤% និងម៉ាស៊ីនច្រូតកាត់ ១% ខេត្តកំពង់ស្ពឺ (៤៨៧២៣គ្រឿង ស្មើ ២១.៦% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត)ឧបករណ៍កសិកម្មនិងគ្រឿងម៉ាស៊ីនភ្ជួររាស់ ៥៣% ឧបករណ៍កសិកម្មផ្សេងទៀតមាន ៤៥% និងម៉ាស៊ីនច្រូតកាត់ ២% និងខេត្តពោធិ៍សាត់ (២៦២៣៧គ្រឿង ស្មើ ២៥.១% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត)ឧបករណ៍កសិកម្មនិងគ្រឿងម៉ាស៊ីនភ្ជួររាស់ ៧១% ឧបករណ៍កសិកម្មផ្សេងទៀតមាន ១៤% ទូកនេសាទ ១៣% និងម៉ាស៊ីនច្រូតកាត់ ២% ។

## ខ. បរិក្ខារសេវាដឹកជញ្ជូន




រូប (១៨) បានបង្ហាញថា៖ ចំនួនប្រភេទនៃបរិក្ខារដឹកជញ្ជូនរបស់ខេត្តបន្ទាយមានជ័យ សរុប (៣៤៧៨គ្រឿង ស្មើ ១.៨% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះរថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និង១២កៅអ៊ី) ១៨% រថយន្តដឹកទំនិញ ៣៣% រថយន្តក្រុង ៣% ម៉ូតូកង់បី ២២% និងទូកដឹកអ្នកដំណើរ ៣% **ខេត្តបាត់ដំបង** សរុប (៤៦៣៨គ្រឿង ស្មើ ២% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះរថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និង១២កៅអ៊ី) ១៤% រថយន្តដឹកទំនិញ ៤៩% រថយន្តក្រុង ២៤% ម៉ូតូកង់បី ៣៤% និងទូកដឹកអ្នកដំណើរ ១% **ខេត្តកំពង់ឆ្នាំង** សរុប(២៧៦៤គ្រឿង ស្មើ១.៨% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះរថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និង១២កៅអ៊ី) ២១% រថយន្តដឹកទំនិញ ៣៨% រថយន្តក្រុង ៦% ម៉ូតូកង់បី ៣៥% និងទូកដឹកអ្នកដំណើរ ១៧% **ខេត្តកំពង់ស្ពឺ** សរុប(៦៦៦៥គ្រឿង ស្មើ ២.៩% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះរថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និង១២កៅអ៊ី) ២៦% រថយន្តដឹកទំនិញ ៤៦% រថយន្តក្រុង ២% ម៉ូតូកង់បី ២៥% និង**ខេត្តពោធិ៍សាត់** សរុប(១៦៥៦គ្រឿង ស្មើ ១.៦% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះរថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និង១២កៅអ៊ី) ២៦% រថយន្តដឹកទំនិញ ៥៧% រថយន្តក្រុង ៤% ម៉ូតូកង់បី ១៣% និងទូកដឹកអ្នកដំណើរ ២% ។

### គ. បរិក្ខារសេវាដឹកជញ្ជូន និងសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន




រូប (១៥) បានបង្ហាញថា៖ ចំនួនប្រភេទនៃបរិក្ខារដឹកជញ្ជូនផ្ទាល់ខ្លួនរបស់ខេត្ត ខេត្តបន្ទាយមានជ័យសរុប(១១២៥២គ្រឿង ដោយស្មើ ៥៨.៦% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះរថយន្តទេសចរណ៍ផ្ទាល់ខ្លួន(គ្រួសារ) ៧% ម៉ូតូ ៨៣% ប្រភេទនៃបរិក្ខារផ្សេងៗ ១០% ខេត្តបាត់ដំបង សរុប(១៧១៨៣៥គ្រឿង ដោយស្មើ ៧៤.២% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះរថយន្តទេសចរណ៍ផ្ទាល់ខ្លួន(គ្រួសារ) ៥% ម៉ូតូ ៨៥% ប្រភេទនៃបរិក្ខារផ្សេងៗ ១១% ខេត្តកំពង់ឆ្នាំង សរុប(១១២៥២គ្រឿង ដោយស្មើ ៦១.៥% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះរថយន្តទេសចរណ៍ផ្ទាល់ខ្លួន(គ្រួសារ) ២% ម៉ូតូ ៦៦% ប្រភេទនៃបរិក្ខារផ្សេងៗ ៣២% ខេត្តកំពង់ស្ពឺ សរុប(១៧០៦៣៦គ្រឿង ដោយស្មើ ៧៥.៥% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះរថយន្តទេសចរណ៍ផ្ទាល់ខ្លួន(គ្រួសារ) ៣% ម៉ូតូ ៧៣% ប្រភេទនៃបរិក្ខារផ្សេងៗ ២៤% និងខេត្តពោធិ៍សាត់ សរុប (៧៦៤៣គ្រឿង ដោយស្មើ ៧៣.៣% នៃប្រភេទនៃបរិក្ខារសរុបរបស់ខេត្ត) ក្នុងនោះរថយន្តទេសចរណ៍ផ្ទាល់ខ្លួន(គ្រួសារ) ៣% ម៉ូតូ ៧៦% ប្រភេទនៃបរិក្ខារផ្សេងៗ ១១%។

## ២.២. អត្រាកំណើត និងមរណភាព

### ២.២.១ អត្រាកំណើត

#### *ក. ទីកន្លែងទារកកើតក្នុងរយៈពេល១២ខែកន្លងមក*

*តារាង(៥) កន្លែងទារកកើតក្នុងរយៈពេល១២ខែកន្លងមកតាមខេត្ត*

| ទីកន្លែងកើត | បន្ទាយមានជ័យ | | បាត់ដំបង | | កំពង់ឆ្នាំង | | កំពង់ស្ពឺ | | ពោធិ៍សាត់ | |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| មន្ទីរពេទ្យរដ្ឋ | ៦.៧០៥ | ៩៥.០ | ១៤.៥៤២ | ៧៧.៨ | ៧.១៦៦ | ៩៧.៨ | ១០.៥២៤ | ៨៩.០ | ៥.៧២៦ | ៩៨.៧ |
| មន្ទីរពេទ្យឯកជន | ២៣៧ | ៣.៤ | ៥០៨ | ២.៧ | ១២២ | ១.៧ | ៨៧៥ | ៧.៤ | ៣២ | ០.៦ |
| ឆ្មបបុរាណ | ១១៩ | ១.៧ | ៣.៦៣៨ | ១៩.៥ | ៤០ | ០.៥ | ៤២៥ | ៣.៦ | ៤១ | ០.៧ |
| សរុប | **៧.០៦១** | **១០០.០** | **១៨.៦៨៨** | **១០០.០** | **៧.៣២៨** | **១០០.០** | **១១.៨២៤** | **១០០.០** | **៥.៧៩៩** | **១០០.០** |

តារាង (៥) បានបង្ហាញភាគរយរបស់ទារកកើតក្នុងរយៈពេល១២ខែកន្លងមក តាមបណ្ដាខេត្តទាំង៥ បន្ទាយមានជ័យសរុប(៧០៦១នាក់) ក្នុងនោះមន្ទីរពេទ្យរដ្ឋ ៩៥% មន្ទីរពេទ្យឯកជន ៣.៤% និងឆ្មបបុរាណ ១.៧% ខេត្តបាត់ដំបងសរុប (១៨៦៨៨នាក់) ក្នុងនោះមន្ទីរពេទ្យរដ្ឋ ៧៧.៨% មន្ទីរពេទ្យឯកជន ២.៧% និងឆ្មបបុរាណ ១៩.៥% **ខេត្តកំពង់ឆ្នាំង** សរុប (៧៣២៨នាក់) ក្នុងនោះមន្ទីរពេទ្យរដ្ឋ ៩៧.៨% មន្ទីរពេទ្យឯកជន ១.៧% និងឆ្មបបុរាណ ០.៥% **ខេត្តកំពង់ស្ពឺ** សរុប (១១៨២៤នាក់) ក្នុងនោះមន្ទីរពេទ្យរដ្ឋ ៨៩.០% មន្ទីរពេទ្យឯកជន ៧.៤% និងឆ្មបបុរាណ ៣.៦% និង**ខេត្តពោធិ៍សាត់** សរុប (៥៧៩៩នាក់) ក្នុងនោះមន្ទីរពេទ្យរដ្ឋ ៩៨.៧% មន្ទីរពេទ្យឯកជន ០.៦% និងឆ្មបបុរាណ ០.៧% ។

## ខ. ទារកកើតក្នុងរយៈពេល១២ខែកន្លងមកតាមភេទ




រូប (១៦) បានបង្ហាញថា៖ អត្រាភាគរយទារកភេទស្រីកើតខ្ពស់ជាងទារកភេទប្រុសគ្រប់ខេត្តទាំងប្រាំ យ៉ាងណាមិញ ខេត្តបន្ទាយមានជ័យ(ទារកប្រុស ៤៩.៨% ទារកស្រី ៥០.២%) **ខេត្តបាត់ដំបង** (ទារកប្រុស ៤៧.៧% ទារកស្រី ៥២.៣%) **ខេត្តកំពង់ឆ្នាំង** (ទារកប្រុស ៤៦.៦% ទារកស្រី ៥៣.៤%) **ខេត្តកំពង់ស្ពឺ** (ទារកប្រុស ៤៧.៩% ទារកស្រី ៥២.១%) និង**ខេត្តពោធិ៍សាត់** (ទារកប្រុស ៤៦.១% ទារកស្រី ៥៣.៩%)។

## ២.២.២ មរណភាព

### ក. ជម្ងឺ

*តារាង(៦)មូលហេតុនៃការស្លាប់រយៈពេល១២ខែកន្លងមកតាមខេត្តទាំង៥*

| មូលហេតុចម្បងនៃការស្លាប់ | បន្ទាយមានជ័យ | បាត់ដំបង | កំពង់ឆ្នាំង | កំពង់ស្ពឺ | ពោធិ៍សាត់ |
|---|---|---|---|---|---|
| 1- ជម្ងឺ | ២.០៣៧ | ៣.៧០០ | ១.៥០៥ | ១.៨៩៩ | ១.៣៥៥ |
| 2- គ្រោះថ្នាក់ចរាចរ | ១៦៤ | ២៥៨ | ១៩៣ | ៣៩២ | ៩៨ |
| 3- លង់ទឹក | ៨៤ | ៦៨ | ៣៣ | ៩០ | ៣៩ |
| 4- ពស់ចឹក | ១៩ | ១១ | ៧ | ១២ | ៤ |
| 5- ឃាតកម្ម | ១៧ | ១៥ | ៧ | ១៤ | ៦ |
| 6- ផ្សេងៗ | ៣២ | ៤៣៣ | ៤៧ | ៣០៦ | ៣២ |
| សរុប | **២.៣១៣** | **៤.៤៨៥** | **១.៧៩២** | **២.៦៦៣** | **១.៥៣៤** |

តារាង (៦) និងរូប (១៧) បានបង្ហាញថាៈ អ្នកស្លាប់សរុបមាន ២៣១៣ នៅខេត្តបន្ទាយមានជ័យ ក្នុងនោះដោយសារជំងឺមានចំនួន ២០៣៧ នាក់ ប្រហែល ៨៨% ខេត្តបាត់ដំបងមានចំនួន ៨៤៨៥ នាក់ក្នុងនោះដោយសារជំងឺមាន ៣៧០០ នាក់ ប្រហែល ៨២% ខេត្តកំពង់ឆ្នាំងមានចំនួន ១៧៤២ នាក់ក្នុងនោះដោយសារជំងឺមាន ១៥០៥ នាក់ ប្រហែល ៨៦% ខេត្តកំពង់ស្ពឺមានចំនួន ២៦៦៣ ក្នុងនោះដោយសារជំងឺមាន ១៨៩៩ នាក់ ប្រហែល ៧១% និងខេត្តពោធិ៍សាត់មានចំនួន ១៥៣៨ ក្នុងនោះដោយសារជំងឺមាន ១៣៥៥ នាក់ ប្រហែល ៨៨% នៃចំនួនអ្នកស្លាប់ប្រចាំខេត្តនិមួយៗ។




*ខ. គ្រោះថ្នាក់ចរាចរណ៍និងលង់ទឹក*



តារាង (៦) និងរូប (១៨) បានបង្ហាញថា៖ អ្នកស្លាប់សរុបមាន ២៣១៣ នៅខេត្តបន្ទាយមានជ័យ ក្នុងនោះដោយសារគ្រោះថ្នាក់ចរាចរណ៍ ៧% និងលង់ទឹក ២% ខេត្តបាត់ដំបង មានចំនួន ៤៤៨៥ នាក់ក្នុងនោះដោយសារគ្រោះថ្នាក់ចរាចរណ៍ ៦% និងលង់ទឹក ២% ខេត្តកំពង់ឆ្នាំងមានចំនួន ១៧៤២ នាក់ ក្នុងនោះដោយសារគ្រោះថ្នាក់ចរាចរណ៍ ៧% និងលង់ទឹក ២% ខេត្តកំពង់ស្ពឺ មានចំនួន ២៦៦៣ ក្នុងនោះដោយសារគ្រោះថ្នាក់ចរាចរណ៍ ១៣% និងលង់ទឹក ៣% និងខេត្តពោធិ៍សាត់ មានចំនួន ១៥៣៤ ក្នុងនោះដោយសារគ្រោះថ្នាក់ចរាចរណ៍ ៦% និងលង់ទឹក ៣%។

## *គ. អ្នកស្លាប់រយៈពេល១២ខែកន្លងមកតាមភេទ*

រូប (១៩) ភាគរយអ្នកស្លាប់នៅក្នុងភូមិ រយៈពេល១២ខែកន្លងមកតាមភេទ និងតាមខេត្តទាំងប្រាំ




រូប (១៩) បានបង្ហាញថា៖ អ្នកស្លាប់សរុបមាន ២៣១៣ នៅខេត្តបន្ទាយមានជ័យ ក្នុងនោះប្រុស ៥២% និងស្រី ៤៨% ខេត្តបាត់ដំបង មានចំនួន ៤៤៨៥ នាក់ក្នុងនោះប្រុស ៥២% និងស្រី ៤៨% ខេត្តកំពង់ឆ្នាំង មានចំនួន ១៧៤២ នាក់ ក្នុងនោះប្រុស ៤៨% និងស្រី ៥២% ខេត្តកំពង់ស្ពឺ មានចំនួន ២៦៦៣ ក្នុងនោះប្រុស ៥៤% និងស្រី ៤៦% និងខេត្តពោធិ៍សាត់ មានចំនួន ១៥៣៤ ក្នុងនោះប្រុស ៥០% និងស្រី ៥០%។

*ឃ. កុមារអាយុក្រោម៥ឆ្នាំស្លាប់រយៈពេល១២ខែកន្លងមក*




រូប(២០)បានបង្ហាញថា៖ អ្នកស្លាប់សរុបមាន២៣១៣នៅខេត្តបន្ទាយមានជ័យ ក្នុងនោះកុមារអាយុក្រោម៥ឆ្នាំ ២.២% ខេត្តបាត់ដំបងមានចំនួន ៨៤៨៥ នាក់ក្នុងនោះកុមារអាយុក្រោម៥ឆ្នាំ ២.៣% ខេត្តកំពង់ឆ្នាំងមានចំនួន ១៧៤២ នាក់ក្នុងនោះកុមារអាយុក្រោម៥ឆ្នាំ ១.៣% ខេត្តកំពង់ស្ពឺមានចំនួន ២៦៦៣ ក្នុងនោះកុមារអាយុក្រោម៥ឆ្នាំ ៤.៩% និងខេត្តពោធិ៍សាត់មានចំនួន ១៥៣៤ ក្នុងនោះកុមារអាយុក្រោម៥ឆ្នាំ ២.៥%។

## ២.៣ ប្រជារាស្ត្រពិការ

### *២.៣.១ ពិការភាពនៃបុគ្គល*

តារាង(៧)ពិការភាពនៃបុគ្គលតាមខេត្តទាំងប្រាំ

| បរិយាយ | បន្ទាយមានជ័យ | បាត់ដំបង | កំពង់ឆ្នាំង | កំពង់ស្ពឺ | ពោធិ៍សាត់ |
|---|---|---|---|---|---|
| បុគ្គលដែលរងគ្រោះដោយសារគ្រាប់មីន | ២.០៧៥ | ២.៤៥៤ | ៤០៨ | ៦០៧ | ៣១២ |
| មនុស្សចាស់ដែលគ្មានអ្នកមើលថៃ | ៤៤៥ | ១.១០៦ | ៧០១ | ៨០៤ | ៤៧២ |
| អនីតិជនដែលពិការ(អាយុក្រោម១៨ឆ្នាំ) | ៤២៤ | ១.០១០ | ៦៨៣ | ៩៧៧ | ៧៨២ |
| បុគ្គលពិការដែលមានប្រភពចំណូល | ១.៣៩៨ | ៣.០២២ | ៨៥៩ | ១.១១៣ | ៦៩១ |
| បុគ្គលពិការដែលគ្មានចំណូល | ៩៩៤ | ១.៥៧៤ | ៥៩៧ | ១.៥៦៧ | ៦៩៣ |

## ក. ការរងគ្រោះដោយសារគ្រាប់មីន




រូប (២១) បានបង្ហាញថា៖ អ្នករងគ្រោះដោយសារគ្រាប់មីនសរុបមាន ២០៧៥ នៅខេត្តបន្ទាយមានជ័យ ក្នុងនោះប្រុស ៨៩% និងស្រី ១១% ខេត្តបាត់ដំបងមានចំនួន ២៩៥៩ នាក់ក្នុងនោះប្រុស ៨៩% និងស្រី ១១% ខេត្តកំពង់ឆ្នាំងមានចំនួន ៥០៨ នាក់ក្នុងនោះប្រុស ៩១% និងស្រី ៩% ខេត្តកំពង់ស្ពឺមានចំនួន ៦០៧ ក្នុងនោះប្រុស ៨៨% និងស្រី ១២% និងខេត្តពោធិ៍សាត់មានចំនួន ៣១២ ក្នុងនោះប្រុស ៩៣% និងស្រី ៧%។

## ខ. មនុស្សចាស់ដែលគ្មានអ្នកមើលថែឬគ្រួសារផ្គត់ផ្គង់




រូប(២២)បានបង្ហាញថា៖ អ្នករងគ្រោះដោយសារគ្រាប់មីនសរុបមាន៥៩៥នៅ ខេត្តបន្ទាយមានជ័យ ក្នុងនោះប្រុស ២៤% និងស្រី ៧៦% ខេត្តបាត់ដំបង មានចំនួន ១១០៦ នាក់

ក្នុងនោះប្រុស ៣៣% និងស្រី ៦៧% ខេត្តកំពង់ឆ្នាំង មានចំនួន ៧០១ នាក់ក្នុងនោះប្រុស ១៨% និងស្រី ៨២% ខេត្តកំពង់ស្ពឺ មានចំនួន ៨០៤ ក្នុងនោះប្រុស ២៨% និងស្រី ៧២% និងខេត្តពោធិ៍សាត់មានចំនួន ៩៧២ ក្នុងនោះប្រុស ១៩% និងស្រី ៨១%។

### *គ. អនីតិជនដែលពិការ(អាយុក្រោម១៨ឆ្នាំ)*




រូប (២៣) បានបង្ហាញថាៈ អនីតិជនដែលពិការ(អាយុក្រោម១៨ឆ្នាំ)សរុបមាន ៨២៨ នៅខេត្តបន្ទាយមានជ័យ ក្នុងនោះប្រុស ៥៣% និងស្រី ៤៧% ខេត្តបាត់ដំបងមានចំនួន ១០១០ នាក់ក្នុងនោះប្រុស ៥៧% និងស្រី ៤៣% ខេត្តកំពង់ឆ្នាំងមានចំនួន ៦៨៣ នាក់ក្នុងនោះប្រុស ៥៤% និងស្រី ៤៦% ខេត្តកំពង់ស្ពឺមានចំនួន ៩៧៧ ក្នុងនោះប្រុស ៥៤% និងស្រី ៤៦% និងខេត្តពោធិ៍សាត់មានចំនួន ៧៨២ ក្នុងនោះប្រុស ៥៥% និងស្រី ៤៥%។

## ឃ. ប្រភពចំណូលជនពិការ




រូប (២៨) បានបង្ហាញថាៈ ចំនួនជនដែលពិការសរុបមាន ២៣៩២ នៅខេត្តបន្ទាយមានជ័យ ក្នុងនោះមានចំណូល ៥៨% និងគ្មានចំណូល ៤២% ខេត្តបាត់ដំបងមានចំនួន ៤៥៩៦ នាក់ក្នុងនោះមានចំណូល ៦៦% និងគ្មានចំណូល ៣៤% ខេត្តកំពង់ឆ្នាំងមានចំនួន ១៤៥៦ នាក់ ក្នុងនោះមានចំណូល ៥៩% និងគ្មានចំណូល ៤១% ខេត្តកំពង់ស្ពឺមានចំនួន ២៦៨០ ក្នុងនោះប្រុស ៥៩% និងស្រី ៤១% និងខេត្តពោធិ៍សាត់មានចំនួន ១៣៣៤ ក្នុងនោះ ប្រុស ៤៨% និងស្រី ៥២%។

## ង. ផ្ទៃដីដែលបានសំអាតគ្រាប់មីន(គិតជាហិកតា)



រូប(២៥)បានបង្ហាញថា៖ ចំនួនផ្ទៃដីដែលបានសំអាតគ្រាប់មីនសរុបមាន ៧២៥៤ ហិកតានៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបងមានចំនួន ៧៨៩៤ ហិកតា ខេត្តកំពង់ឆ្នាំងមានចំនួន ៥៥ ហិកតា ខេត្តកំពង់ស្ពឺមានចំនួន ១៩៦៣ ហិកតា និងខេត្តពោធិ៍សាត់មានចំនួន ៣៩៥ ហិកតា។

## ២.៤ ការប្រើប្រាស់ទឹក និងអនាម័យ

តារាង (៨) ប្រភពទឹកប្រើប្រាស់ដោយគ្រួសារ

| បរិយាយ | បន្ទាយមានជ័យ | បាត់ដំបង | កំពង់ឆ្នាំង | កំពង់ស្ពឺ | ពោធិ៍សាត់ |
|---|---|---|---|---|---|
| គ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ) | ៤០.៤១៤ | ៥២.៩១៩ | ១៧.៨៣២ | ២៥.១៥៩ | ១៣.១៤០ |
| គ្រួសារដែលមានអណ្តូង | ២០.៨១២ | ៤៩.៥៤៦ | ៧៨.៦២៣ | ៤០.៧៥១ | ៣៣.១២៧ |
| គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ | ៣៧.៣០៣ | ៤១.០៥៥ | ៤.២២៩ | ២៧.៣៤៩ | ១១.៩១៩ |
| គ្រួសារបានប្រើប្រាស់ទឹកស្រះ /បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ | ១០៤.៤៨២ | ៩៦៩៧៩ | ១៦.៨៥២ | ៨៦.៤៧៦ | ៤៩.២៥៥ |
| គ្រួសារមានបង្គន់អនាម័យផ្ទាល់ខ្លួន | ១០៥.៩៨៣ | ១៦២.១២៩ | ៥៤.៥៥០ | ៨៤.៩៦៦ | ៥.៤៥០០ |
| គ្រួសារសរុប | ១៨១.២៦១ | ២៥០.៩៨០ | ១២៤.២០៩ | ១៧៦.២១១ | ១០៨.៦៤៣ |

### *ក. ការប្រើប្រាស់ទឹក*



រូប (២៦) ភាគរយនៃការប្រើប្រាស់ទឹករបស់គ្រួសារតាមខេត្តទាំងប្រាំ

រូប(២៦)បានបង្ហាញថា៖ **ខេត្តបន្ទាយមានជ័យ** ចំណោមគ្រួសារសរុប(១៨១២៦១គ្រួសារ) ក្នុងនោះមានមេគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ) ២២% គ្រួសារដែលមានអណ្តូង (១១%) គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ២១% និងគ្រួសារបានប្រើប្រាស់ទឹកស្រះ /បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ៥៨% **ខេត្តបាត់ដំបង** ចំណោមគ្រួសារសរុប (២៥០៩៨០) ក្នុងនោះមានគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ (ទុយោ) ២១% គ្រួសារដែលមានអណ្តូង (២០%) គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ១៦% និងគ្រួសារបានប្រើប្រាស់ទឹកស្រះ /បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ៣៩% **ខេត្តកំពង់ឆ្នាំង** ចំណោមគ្រួសារសរុប (១២៤២០៩) ក្នុងនោះមានគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ) ១៤% គ្រួសារដែលមានអណ្តូង (៦៣%) គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ៣% និងគ្រួសារបានប្រើប្រាស់ទឹកស្រះ /បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ១៤% **ខេត្តកំពង់ស្ពឺ**ក្នុងចំណោមមេគ្រួសារសរុប (១៧៦២១១) ក្នុងនោះមានគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ)១៤% គ្រួសារដែលមានអណ្តូង (២៣%) គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ១៦% និងគ្រួសារបានប្រើប្រាស់ទឹកស្រះ /បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ៤៩% និង**ខេត្តពោធិ៍សាត់** ចំណោមមេគ្រួសារសរុប (១០៨៦៤៣) ក្នុងនោះមានមេគ្រួសារដែលទទួលបានទឹកស្អាតបរិភោគ(ទុយោ)១២% គ្រួសារដែលមានអណ្តូង (៣០%) គ្រួសារប្រើប្រាស់ទឹកភ្លៀងសម្រាប់បរិភោគ ១១% និងគ្រួសារបានប្រើប្រាស់ទឹកស្រះ /បឹង/ស្ទឹង/ទន្លេ សម្រាប់បរិភោគ ៤១% ។

### *ខ. អនាម័យ*

**រូប (២៧) ភាគរយនៃគ្រួសារមានបង្គន់អនាម័យផ្ទាល់ខ្លួនតាមខេត្តទាំងប្រាំ**




រូប(២៧)បានបង្ហាញថា៖ **ខេត្តបន្ទាយមានជ័យ** ចំណោមគ្រួសារសរុប (១៨១២៦១គ្រួសារ) ក្នុងនោះមានបង្គន់អនាម័យផ្ទាល់ ៥៨% **ខេត្តបាត់ដំបង** ចំណោមគ្រួសារសរុប(២៥០៩៨០) ក្នុងនោះមានបង្គន់អនាម័យផ្ទាល់ ៦៥% **ខេត្តកំពង់ឆ្នាំង** ចំណោមគ្រួសារសរុប (១២៤២០៩) ក្នុងនោះមាន

បង្គន់អនាម័យផ្ទាល់ ៤៤% **ខេត្តកំពង់ស្ពឺ** ក្នុងចំណោមគ្រួសារសរុប (១៧៦២១១) ក្នុងនោះមានបង្គន់ អនាម័យផ្ទាល់ ៤៨% និង**ខេត្តពោធិ៍សាត់** ចំណោមមេគ្រួសារសរុប (១០៨៦៤៣) ក្នុងនោះបង្គន់ អនាម័យផ្ទាល់ ៥០%។

### *គ. គ្រួសារដែលគ្មានផ្ទះសម្បែង*




រូប(២៧) បានបង្ហាញថា៖ ខេត្តបន្ទាយមានជ័យ ចំណោមគ្រួសារសរុប (១៨១.២៦១គ្រួសារ) ក្នុងនោះ មានគ្រួសារដែលរស់នៅលើដីសាធារណៈ ២.១% និងគ្រួសារដែលគ្មានផ្ទះសម្បែង ១.២% ខេត្តបាត់ដំបង ចំណោមគ្រួសារសរុប (២៥០៩៨០) ក្នុងនោះមានគ្រួសារដែលរស់នៅលើដីសាធារណៈ ៣.១% និងគ្រួសារ ដែលគ្មានផ្ទះសម្បែង ០.៤% ខេត្តកំពង់ឆ្នាំង ចំណោមគ្រួសារសរុប (១២៤២០៩) ក្នុងនោះមានគ្រួសារដែល រស់នៅលើដីសាធារណៈ ៣.៣% និងគ្រួសារដែលគ្មានផ្ទះសម្បែង ០.២% ខេត្តកំពង់ស្ពឺ ក្នុងចំណោមគ្រួសារ សរុប (១៧៦២១១) ក្នុងនោះមានគ្រួសារដែលរស់នៅលើដីសាធារណៈ ០.៦% និងគ្រួសារដែលគ្មានផ្ទះសម្បែង ០.៣% និងខេត្តពោធិ៍សាត់ ចំណោមមេគ្រួសារសរុប (១០៨៦៤៣) ក្នុងនោះមានគ្រួសារដែលរស់នៅលើដី សាធារណៈ ៤.៥% និងគ្រួសារដែលគ្មានផ្ទះសម្បែង ០.៣%។

## ២.៥ បរិស្ថាន និងធនធានធម្មជាតិ

*ក. ទីតាំងរបស់ផ្ទៃដីចោលសំរាម*




រូប (២៩) បានបង្ហាញថា៖ **ខេត្តបន្ទាយមានជ័យ** មានផ្ទៃដីចោលសំរាបមាន ២៤ហិកតា **ខេត្តបាត់ដំបង** មាន១៥ហិកតា **ខេត្តកំពង់ឆ្នាំង** មាន ៨៨ហិកតា **ខេត្តកំពង់ស្ពឺ** មាន ១៣ហិកតា និង**ខេត្តពោធិ៍សាត់** មាន ១២៧ ហិកតា ។

*ខ. ទីតាំងរបស់ផ្ទៃដីចោលកាកសំណល់ឧស្សាហកម្ម*




រូប(៣១)បានបង្ហាញថា៖ **ខេត្តបន្ទាយមានជ័យ** មានផ្ទៃដីចោលកាកសំណល់ឧស្សាហកម្មមាន៧ ហិកតា **ខេត្តបាត់ដំបង** មានផ្ទៃដីចោលកាកសំណល់ឧស្សាហកម្មមាន៦ហិកតា **ខេត្តកំពង់ឆ្នាំង** មាន

ផ្ទៃដីចោលកាកសំណល់ឧស្សាហកម្មមាន ២២៧ហិកតា**ខេត្តកំពង់ស្ពឺ** មានផ្ទៃដីចោលកាកសំណល់ឧស្សាហកម្មមាន៣៣ហិកតា និង **ខេត្តពោធិ៍សាត់**មិនមាន។

### *គ. ទីតាំងរោងចក្រ*

**រូប (៣១) ផ្ទៃដីទីតាំងរោងចក្រ គិតជាហិកតា និងតាមខេត្តទាំងប្រាំ**




រូប (៣១) បានបង្ហាញពីក្រលាផ្ទៃដីទីតាំងរោងចក្រ ក្នុងនោះខេត្តបន្ទាយមានជ័យ ២៥ ហិកតា ខេត្តបាត់ដំបង ៣៦ ហិកតា ខេត្តកំពង់ឆ្នាំង ៨៤ ហិកតា ខេត្តកំពង់ស្ពឺ ៤៤៨ ហិកតា និង ពោធិ៍សាត់ មិនមាន។

### *ឃ. ការចម្អិនអាហាររបស់គ្រួសារ*

**រូប (៣២) ភាគរយនៃគ្រួសារដែលប្រើប្រាស់អុស/ធ្យូង តាមខេត្តទាំងប្រាំ**




រូប(៣២)បានបង្ហាញថា៖ ខេត្តបន្ទាយមានជ័យ ចំណោមគ្រួសារសរុប (១៨១២៦១គ្រួសារ) ក្នុងនោះគ្រួសារដែលប្រើប្រាស់អុស/ធ្យូង ៧៨% ខេត្តបាត់ដំបង ចំណោមគ្រួសារសរុប(២៥០៩៨០) មានគ្រួសារដែលប្រើប្រាស់អុស/ធ្យូង ៧៧% ខេត្តកំពង់ឆ្នាំង ចំណោមគ្រួសារសរុប (១២៤២០៩) មានគ្រួសារដែលប្រើប្រាស់អុស/ធ្យូង ៩២% ខេត្តកំពង់ស្ពឺ ក្នុងចំណោមគ្រួសារសរុប (១៧៦២១១)

មានគ្រួសារដែលប្រើប្រាស់អុស/ធ្យូង ៨៧% និងខេត្តពោធិ៍សាត់ ចំណោមមេគ្រួសារសរុប (១០៨៦៤៣) មានគ្រួសារដែលប្រើប្រាស់អុស/ធ្យូង ៩៤% ។

### *ង. ធនធានធម្មជាតិ*

*តារាង(៩)ធនធានធម្មជាតិ*

| បរិយាយ | បន្ទាយមានជ័យ | បាត់ដំបង | កំពង់ឆ្នាំង | កំពង់ស្ពឺ | ពោធិ៍សាត់ |
|---|---|---|---|---|---|
| ព្រៃឈើគ្របដណ្តប់ | ៦.៣០៥ | ៤៣.១៩៧ | ១១.៧៨៣ | ១១.៤០៨ | ២០.៤៩៦ |
| ការដាំកូនឈើ | ៤.៥២៦ | ៨៨៦ | ៧២១ | ១៣៧ | ២.១៣៦ |
| ការកាប់ឆ្ការព្រៃ | ៤១០ | ៩.៨៨៨ | ៦១៩ | ៥១២ | ៣.០៧៧ |

តារាង(៩)បានបង្ហាញឲ្យដឹងថា៖ពីព្រៃឈើគ្របដណ្តប់ ការដាំកូនឈើ និងការកាប់ឆ្ការព្រៃ ក្នុងនោះខេត្តបន្ទាយមានជ័យ ព្រៃឈើគ្របដណ្តប់៦៣០៥ហិកតា ការដាំកូនឈើ ៤៥២៦ហិកតា និងការកាប់ឆ្ការព្រៃ ៤១០ហិកតា ខេត្តបាត់ដំបង មានព្រៃឈើគ្របដណ្តប់៤៣១៩៧ហិកតា ការដាំកូនឈើ ៨៨៦ហិកតា និងការកាប់ឆ្ការព្រៃ ៩៨៨៨ហិកតា ខេត្តកំពង់ឆ្នាំង មានព្រៃឈើគ្របដណ្តប់១១៧៨៣ហិកតា ការដាំកូនឈើ ៧២១ហិកតា និងការកាប់ឆ្ការព្រៃ ៦១៩ហិកតា ខេត្តកំពង់ស្ពឺ មានព្រៃឈើគ្របដណ្តប់១១៤០៨ហិកតា ការដាំកូនឈើ ១៣៧ហិកតា និងការកាប់ឆ្ការព្រៃ ៥១២ហិកតា និងខេត្តពោធិ៍សាត់មានព្រៃឈើគ្របដណ្តប់២០៤៩៦ហិកតា ការដាំកូនឈើ ២១៣៦ហិកតា និងការកាប់ឆ្ការព្រៃ ៣០៧៧ហិកតា។

## ២.៦ គ្រោះធម្មជាតិ

### *ក. គ្រួសារដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ*

*តារាង(១០)គ្រួសារដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ តាមខេត្តទាំង៥*

| គ្រោះធម្មជាតិ | ទឹកជំនន់ | គ្រោះរាំងស្ងួត | ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ |
|---|---|---|---|
| បន្ទាយមានជ័យ | ៦៨៣ | ៨៩.៩៤០ | ១.៥៧៨ |
| បាត់ដំបង | ៥.៦៣៩ | ៤៤.៨៥៩ | ២.៧០៥ |
| កំពង់ឆ្នាំង | ១៤៧ | ២០.១៧២ | ៤៣២ |
| កំពង់ស្ពឺ | ៦៦០ | ១៣.៤៦៤ | ៣.១៩១ |
| ពោធិ៍សាត់ | ១.០៤០ | ២៩.៨៤៤ | ១.៣៦៩ |

តារាង(១០)បានបង្ហាញឲ្យដឹងថា៖គ្រួសារដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ ក្នុងនោះ ខេត្តបន្ទាយមានជ័យ រងគ្រោះដោយទឹកជំនន់៦៨៣គ្រួសារ គ្រោះរាំងស្ងួត៤៤៨៥៩គ្រួសារ និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់១៥៧៨គ្រួសារ ខេត្តបាត់ដំបង រងគ្រោះដោយទឹកជំនន់៥៦៣៩គ្រួសារ គ្រោះរាំងស្ងួត ៤៤៨៥៩គ្រួសារ និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់២០១៧២គ្រួសារ ខេត្តកំពង់ឆ្នាំង រងគ្រោះដោយទឹកជំនន់ ១៤៧គ្រួសារ គ្រោះរាំងស្ងួត២០១៧២គ្រួសារ និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់៤៣២គ្រួសារ ខេត្តកំពង់ស្ពឺ រងគ្រោះដោយទឹកជំនន់៦៦០គ្រួសារ គ្រោះរាំងស្ងួត១៣៤៦៤គ្រួសារ និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់៣១៦៩ គ្រួសារ និង ខេត្តពោធិ៍សាត់ រងគ្រោះដោយទឹកជំនន់១០៤០គ្រួសារ គ្រោះរាំងស្ងួត២៩៨៤៤គ្រួសារ និង ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់១៣៦៩គ្រួសារ។

### *ខ. ផ្ទៃដីដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ*

*តារាង(១១)ផ្ទៃដីដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ តាមខេត្តទាំង៥(គិតជាហិកតា)*

| គ្រោះធម្មជាតិ | ទឹកជំនន់ | គ្រោះរាំងស្ងួត | ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ |
|---|---|---|---|
| បន្ទាយមានជ័យ | ១.១០២ | ២២៩.២៣០ | ៦៧២ |
| បាត់ដំបង | ១១.២៤៥ | ១៣៣.៥៧៥ | ៨.៦៥៩ |
| កំពង់ឆ្នាំង | ៤៩១ | ១៩.៩៤០ | ៤១.៥២២ |
| កំពង់ស្ពឺ | ២១១ | ២៧.៣២៨ | ២.២៧៨ |
| ពោធិ៍សាត់ | ១.៧១៦ | ៥៦.៥០៦ | ២.០០៩ |

តារាង (១១) បានបង្ហាញឲ្យដឹងថា៖ផ្ទៃដីដែលមានផលប៉ះពាល់ដោយគ្រោះធម្មជាតិ ក្នុងនោះ **ខេត្តបន្ទាយមានជ័យ** រងគ្រោះដោយទឹកជំនន់១១០២ហិកតា គ្រោះរាំងស្ងួត២២៩២៣០ហិកតា និង

ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់៦៧២ហិកតា **ខេត្តបាត់ដំបង** រងគ្រោះដោយទឹកជំនន់ ១១២៤៥ ហិកតា គ្រោះរាំងស្ងួត២២៩២៣០ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ៨៦៥៩ ហិកតា **ខេត្តកំពង់ឆ្នាំង** រងគ្រោះដោយទឹកជំនន់ ៤៩១ ហិកតា គ្រោះរាំងស្ងួត ១៩៩៤ ០ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ៤១៥២២ហិកតា **ខេត្តកំពង់ស្ពឺ** រងគ្រោះដោយទឹកជំនន់ ២១១ហិកតា គ្រោះរាំងស្ងួត ២៧៣២៨ ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់២២៧៨ហិកតា និង **ពោធិ៍សាត់** រងគ្រោះដោយទឹកជំនន់ ១៧១៦ ហិកតា គ្រោះរាំងស្ងួត ៥៦៥០៦ ហិកតា និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ២០០៩ ហិកតា។

## ២.៧ សន្តិសុខសង្គម និងសេដ្ឋកិច្ច

### *២.៧.១អសន្តិសុខសង្គម*

បញ្ហាសន្តិសុខសង្គមសំដៅលើការ ករណីលួច ប្លន់ ចាប់ជំរិតនិងឧក្រិដ្ឋកម្ម ប្រើប្រាស់គ្រឿងញៀនជម្លោះដីធ្លីនៅក្នុងមូលដ្ឋាន។ ចំពោះករណីទាំងអស់នោះទោះបីជាមានចំនួនកើតឡើងច្រើនករណីក៏ដោយរាជរដ្ឋាភិបាលនៅតែខិតខំដោះស្រាយបានមួយចំនួនធំដែរ ដូច្នេះតួលេខបានបង្ហាញដូចខាងក្រោមនេះ។

*ក. ករណីលួចឆក់*

**រូប (៣៣) ករណីលួចឆក់តាមខេត្តទាំងប្រាំ**




រូប(៣៣)បានបង្ហាញថា៖ ខេត្តបន្ទាយមានជ័យ ករណីលួចសរុប១៨៨ករណី ក្នុងនោះ បានដោះស្រាយ ៦៧ករណី ខេត្តបាត់ដំបង ករណីលួចសរុប៦៦៩ករណី ក្នុងនោះបានដោះស្រាយ ៤៤៦ករណី ខេត្តកំពង់ឆ្នាំង ករណីលួចសរុប១៩១ករណី ក្នុងនោះបានដោះស្រាយ ១០០ករណី ខេត្តកំពង់ស្ពឺ ករណីលួចសរុប៤០៨ករណី ក្នុងនោះបានដោះស្រាយ ១៩៦ករណី និងខេត្តពោធិ៍សាត់ ករណីលួចសរុប២៥៨ករណី ក្នុងនោះបានដោះស្រាយ ៧៩ករណី ។

## *ខ. ករណីឃាត្តកម្ម ប្លន់និងឧក្រិដ្ឋកម្ម*




រូប(៣៤)បានបង្ហាញថា៖ **ខេត្តបន្ទាយមានជ័យ** ឃាត្តកម្ម ប្លន់ ចាប់ជម្រិត និងឧក្រិដ្ឋកម្មសរុប ២៨ករណី បានដោះស្រាយ ១៥ករណី **ខេត្តបាត់ដំបង** ឃាត្តកម្ម ប្លន់ ចាប់ជម្រិត និងឧក្រិដ្ឋកម្មសរុប៤៥ ករណី បានដោះស្រាយ៤០ករណី **ខេត្តកំពង់ឆ្នាំង** ឃាត្តកម្ម ប្លន់ ចាប់ជម្រិត និងឧក្រិដ្ឋកម្មសរុប១០ ករណី បានដោះស្រាយ៨ករណី **ខេត្តកំពង់ស្ពឺ** ឃាត្តកម្ម ប្លន់ ចាប់ជម្រិត និងឧក្រិដ្ឋកម្មសរុប៦១ករណី បានដោះស្រាយ៤២ករណី និង**ខេត្តពោធិ៍សាត់** ឃាត្តកម្ម ប្លន់ ចាប់ជម្រិត និងឧក្រិដ្ឋកម្មសរុប១៥ករណី បានដោះស្រាយទាំង ១៥ ករណី។

## *គ. ជម្លោះដីធ្លី*




រូប(៣៥)បានបង្ហាញថា៖ ខេត្តបន្ទាយមានជ័យ ជម្លោះរឿងដីធ្លីសរុប ៦២៣ ករណី ដោះស្រាយបាន ៣៣០ ករណី ខេត្តបាត់ដំបង ជម្លោះរឿងដីធ្លីសរុប ៩៧៣ ករណី ដោះស្រាយបាន ៧២៧ ករណី ខេត្តកំពង់ឆ្នាំង ជម្លោះរឿងដីធ្លីសរុប ៦៩០ ករណី ដោះស្រាយបាន៦១៣ករណី ខេត្តកំពង់ស្ពឺ ជម្លោះរឿងដីធ្លីសរុប ៦៦៥ ករណី ដោះស្រាយបាន ៤៧៦ ករណី និងខេត្តពោធិ៍សាត់ ជម្លោះរឿងដីធ្លីសរុប ៩៩០ ករណី ដោះស្រាយបាន៦៣៥ករណី។

### *ឃ. ការទាស់ទែងគ្នារបស់ប្រជាពលរដ្ឋ*

**រូប (៣៦) ចំនួនករណីប្រជាពលរដ្ឋទាស់ទែងគ្នាតាមខេត្តទាំងប្រាំ**




រូប(៣៦)បានបង្ហាញថា៖ ខេត្តបន្ទាយមានជ័យចំនួនករណីនៃការទាស់ទែងគ្នារបស់ប្រជាពលរដ្ឋសរុបចំនួន ៩១៩ ករណី ដោះស្រាយបាន ៥៩៨ ករណី ខេត្តបាត់ដំបង ចំនួនករណីប្រជាពលរដ្ឋទាស់ទែងគ្នាសរុប ១១៧៦ ករណី ដោះស្រាយបាន ១០៦៦ ករណី ខេត្តកំពង់ឆ្នាំង ចំនួនករណីប្រជាពលរដ្ឋទាស់ទែងគ្នាសរុប ៨៦៨ ករណី ដោះស្រាយបាន ៧៩២ ករណីខេត្តកំពង់ស្ពឺ ចំនួនករណីប្រជាពលរដ្ឋទាស់ទែងគ្នាសរុប ១២០៤ ករណី ដោះស្រាយបាន ១០៧៧ ករណី និងខេត្តពោធិ៍សាត់ ចំនួនករណីប្រជាពលរដ្ឋទាស់ទែងគ្នាសរុប ៥៩៥ ករណី ដោះស្រាយបាន ៥៤៩ ករណី។

## *ង. អំពើហិង្សាក្នុងគ្រួសារនិងគ្រឿងញៀន*

**រូប(៣៧) ភាគរយគ្រួសារប្រើហឹង្សា និងគ្រឿងញៀន តាមខេត្តទាំងប្រាំ**




រូប(៣៧)បានបង្ហាញថា៖ ចំណោមគ្រួសារនៅ**ខេត្តបន្ទាយមានជ័យ** ១០០០ គ្រួសារ នោះ៥គ្រួសារជួបអំពើហិង្សាក្នុងគ្រួសារ និង៥គ្រួសារប្រើប្រាស់គ្រឿងញៀន **ខេត្តបាត់ដំបង**ចំណោម ១០០០ គ្រួសារ នោះ៦គ្រួសារជួបអំពើហិង្សាក្នុងគ្រួសារ និង៨គ្រួសារដែលប្រើប្រាស់គ្រឿងញៀន **ខេត្តកំពង់ឆ្នាំង** ១០០០ គ្រួសារ ក្នុងនោះមាន៨គ្រួសារជួបអំពើហិង្សាក្នុងគ្រួសារ និង២គ្រួសារប្រើប្រាស់គ្រឿងញៀន **ខេត្តកំពង់ស្ពឺ** ១០០០ គ្រួសារ ក្នុងនោះមាននោះ៩គ្រួសារជួបអំពើហិង្សាក្នុងគ្រួសារ និង៥គ្រួសារប្រើប្រាស់គ្រឿងញៀន និង**ខេត្តពោធិ៍សាត់** ១០០០គ្រួសារ ក្នុងនោះមាន៨គ្រួសារជួបអំពើហិង្សាក្នុងគ្រួសារ និង៣គ្រួសារប្រើប្រាស់គ្រឿងញៀន ។

## ចៈ ស្ត្រីរងគ្រោះដោយសារការចាប់រំលោភនិងជួញដូរ

រូប(៣៨)ចំនួនស្ត្រីរងគ្រោះដោយសារការចាប់រំលោភ និងជួញដូរតាមខេត្ត




រូប(៣៨)បានបង្ហាញថាៈ **ខេត្តបន្ទាយមានជ័យ** មានស្ត្រីរងគ្រោះចំនួន២២ករណី (ការចាប់រំលោភ២១និងជួញដូរ១) **ខេត្តបាត់ដំបង** មានស្ត្រីរងគ្រោះចំនួន៥០ករណី (ការចាប់រំលោភ៤៩និងជួញដូរ១) **ខេត្តកំពង់ឆ្នាំង** មានស្ត្រីរងគ្រោះចំនួន៣០ករណី (ការចាប់រំលោភ២៨និងជួញដូរ២) **ខេត្តកំពង់ស្ពឺ** មានស្ត្រីរងគ្រោះចំនួន៣១ករណី (ការចាប់រំលោភ២៩និងជួញដូរ២) និង**ខេត្តពោធិ៍សាត់** មានស្ត្រីរងគ្រោះចំនួន២១ករណី (ការចាប់រំលោភ២១និងជួញដូរ១)។

## ឆៈ ស្ត្រីរងគ្រោះដោយសារការចាប់រំលោភនិងជួញដូរតាមក្រុមអាយុ

រូប(៣៩)ចំនួនស្ត្រីរងគ្រោះដោយសារការចាប់រំលោភ និងជួញដូរតាមក្រុមអាយុ និងតាមខេត្ត



រូប(៣៩)បានបង្ហាញថា៖ **ខេត្តបន្ទាយមានជ័យ** មានស្ត្រីរងគ្រោះដោយសារចាប់រំលោភនិងជួញដូរចំនួន២២ករណី (ការចាប់រំលោភអាយុក្រោម១៨ឆ្នាំ ចំនួន១៥ករណី) **ខេត្តបាត់ដំបង** មានស្ត្រីរងគ្រោះចំនួន៥០ករណី (ការចាប់រំលោភអាយុក្រោម១៨ឆ្នាំ ចំនួន៣០ករណី) **ខេត្តកំពង់ឆ្នាំង** មានស្ត្រីរងគ្រោះចំនួន៣០ករណី (ការចាប់រំលោភអាយុក្រោម១៨ឆ្នាំ ចំនួន១៥ករណី) **ខេត្តកំពង់ស្ពឺ** មានស្ត្រីរងគ្រោះចំនួន៣១ករណី (ការចាប់រំលោភអាយុក្រោម១៨ឆ្នាំ ចំនួន១៥ករណី) និង**ខេត្តពោធិ៍សាត់** មានស្ត្រីរងគ្រោះចំនួន២១ករណី (ការចាប់រំលោភអាយុក្រោម១៨ឆ្នាំ ចំនួន១២ករណីនិងការជួញដូរ១ករណីផងដែរ) ។

### ២.៧.២ស្ថានភាពសេដ្ឋកិច្ចគ្រួសារ

សកម្មភាពអាជីវកម្មចម្បងរបស់គ្រួសារក្រៅពីរបរកសិកម្ម រូប(៤០)បានបង្ហាញថា៖ **ខេត្តបន្ទាយមានជ័យ** ៩៧៨៤គ្រួសារ **ខេត្តបាត់ដំបង ១២៩១៦**គ្រួសារ **ខេត្តកំពង់ឆ្នាំង** ១០៣៧៨គ្រួសារ **ខេត្តកំពង់ស្ពឺ** ១១៩៥៥គ្រួសារ និង**ខេត្តពោធិ៍សាត់** ៩៣៧៥គ្រួសារ។




### ក. ម៉ាស៊ីនកិនស្រូវ



សកម្មភាពអាជីវកម្មម៉ាស៊ីនកិនស្រូវ(រូប៤១)ខេត្តបន្ទាយមានជ័យ មានចំនួន៥៩៥គ្រួសារ ខេត្តបាត់ដំបង ចំនួន៦៨២គ្រួសារ ខេត្តកំពង់ឆ្នាំងចំនួន២៤៧៥គ្រួសារ ខេត្តកំពង់ស្ពឺ ចំនួន២៩៩៨គ្រួសារ និងខេត្តពោធិ៍សាត់ចំនួន២២៣៤គ្រួសារ។

### ខ. ផ្នែកសណ្ឋាគារ ផ្ទះសំណាក់និងភោជនីយដ្ឋាន




សកម្មភាពអាជីវកម្មសណ្ឋាគារ ផ្ទះសំណាក់និងភោជនីយដ្ឋាន(រូប៤២) ខេត្តបន្ទាយមានជ័យ ១៧៧គ្រួសារ ខេត្តបាត់ដំបង ២៨៨គ្រួសារ ខេត្តកំពង់ឆ្នាំង ១១៥គ្រួសារ ខេត្តកំពង់ស្ពឺ ១២២គ្រួសារ និងខេត្តពោធិ៍សាត់ ៨៧គ្រួសារ។

## គ. អាជីវកម្មជួសជុលម៉ាស៊ីនគ្រប់ប្រភេទ




សកម្មភាពអាជីវកម្មអាជីវកម្មជួសជុលម៉ាស៊ីនគ្រប់ប្រភេទ(រូប៤៣) ខេត្តបន្ទាយមានជ័យ ១៥៦២គ្រួសារ ខេត្តបាត់ដំបង ១៨៨៨គ្រួសារ ខេត្តកំពង់ឆ្នាំង ១១៤០គ្រួសារ ខេត្តកំពង់ស្ពឺ ១៦១៦គ្រួសារ និងខេត្តពោធិ៍សាត់ ១០៤៦គ្រួសារ។

## ឃ. អាជីវកម្មគ្រឿងសំណង់និងសង្ហារឹម




សកម្មភាពអាជីវកម្មអាជីវកម្មលក់គ្រឿងសំណង់និងសង្ហារឹម(រូប៤៤) ខេត្តបន្ទាយមានជ័យ ៤៧២ គ្រួសារ ខេត្តបាត់ដំបង ៨១៣គ្រួសារ ខេត្តកំពង់ឆ្នាំង ៣៩៧គ្រួសារ ខេត្តកំពង់ស្ពឺ ៧០៣គ្រួសារ និងខេត្តពោធិ៍សាត់ ៥៦៧គ្រួសារ។

## ង. លក់គ្រឿងទេសនិងភេសជ្ជៈ ថ្នាំពេទ្យ និងគ្លីនិក




សកម្មភាពអាជីវកម្មលក់គ្រឿងទេសនិងភេសជ្ជៈ ថ្នាំពេទ្យ និងគ្លីនិក(រូប៤៥) **ខេត្តបន្ទាយមានជ័យ** ៣៤៦៤គ្រួសារ **ខេត្តបាត់ដំបង** **៤០៩៥**គ្រួសារ **ខេត្តកំពង់ឆ្នាំង** ២៩០១គ្រួសារ **ខេត្តកំពង់ស្ពឺ** ៣០៣៤គ្រួសារ និង**ខេត្តពោធិ៍សាត់** ២៥១២គ្រួសារ។

## ច. គ្រួសារមានស្ថានីយចាក់ប្រេងឥន្ធនៈគ្រប់កម្រិត



សកម្មភាពអាជីវកម្មគ្រួសារដែលមានស្ថានីយចាក់ប្រេងឥន្ធនៈគ្រប់កម្រិត(រូប៤៦) ខេត្តបន្ទាយមានជ័យ ២៤៧៧គ្រួសារ ខេត្តបាត់ដំបង ៣៨២៦គ្រួសារ ខេត្តកំពង់ឆ្នាំង ២៤៨៣គ្រួសារ ខេត្តកំពង់ស្ពឺ ២៤៩២ គ្រួសារ និងខេត្តពោធិ៍សាត់ ២៤៥៦គ្រួសារ។

### ឆ. តូបកាត់សក់ ឬអ៊ុតសក់ និងអាជីវកម្មផ្សេងទៀត




សកម្មភាពអាជីវកម្មគ្រួសារដែលមានតូបកាត់សក់ ឬអ៊ុតសក់ និងអាជីវកម្មផ្សេងទៀត(មើលរូបៈ៤៧) ខេត្តបន្ទាយមានជ័យ ១០៣៧គ្រួសារ ខេត្តបាត់ដំបង ១៣២៤គ្រួសារ ខេត្តកំពង់ឆ្នាំង ៨៦៧គ្រួសារ ខេត្តកំពង់ស្ពឺ ៩៩០គ្រួសារ និងខេត្តពោធិ៍សាត់ ៤៧៣គ្រួសារ។

## ២.៦.២លំហូរវិនិយោគតាមប្រភេទ នៃសកម្មភាពអភិវឌ្ឍន៍




លំហូរវិនិយោគតាមប្រភេទនៃសកម្មភាពអភិវឌ្ឍន៍ (រូប៤៨) ខេត្តបន្ទាយមានជ័យ មានហេដ្ឋារចនាសម្ព័ន្ធ ៣១៦ កសិកម្ម ៨៨ និងធារាសាស្ត្រ ៣៥ ខេត្តបាត់ដំបង មានហេដ្ឋារចនាសម្ព័ន្ធ ២៤៨ កសិកម្ម ៣៤០ និងធារាសាស្ត្រ ៨៦ ខេត្តកំពង់ឆ្នាំង មានហេដ្ឋារចនាសម្ព័ន្ធ ២៤៨ កសិកម្ម ៣៤០ និងធារាសាស្ត្រ ៤០ ខេត្តកំពង់ស្ពឺ មានហេដ្ឋារចនាសម្ព័ន្ធ ១៤៧ កសិកម្ម ៤៤១ និងធារាសាស្ត្រ ៣២ និងខេត្តពោធិ៍សាត់ មានហេដ្ឋារចនាសម្ព័ន្ធ ២៥០កសិកម្ម ១១២៩ និងធារាសាស្ត្រ ៥២។

## ២.៨.ទិស័យអប់រំ និងសេវាសង្គម

### *២.៨.១ ផ្នែកសិក្សាអប់រំ*

នៅក្នុងផ្នែកសិក្សាអប់រំនៅក្នុងអត្ថបទនេះ គឺសំដៅលើចំនួននិងចម្ងាយពីភូមិទីតាំងដែលផ្តល់សេវាអប់រំដល់ប្រជាពលរដ្ឋនៅទូទាំង៥ខេត្ត។ កន្លែងមតេយ្យសហគមន៍ សាលាមតេយ្យ សាលាបឋមសិក្សា សាលាអនុវិទ្យាល័យ វិទ្យាល័យ និងសាកលវិទ្យាល័យរដ្ឋ ទាំងរដ្ឋនិងឯកជន។

#### *២.៨.១.១ ចំនួនគ្រឹះស្ថានសិក្សា*

#### *ក. ចំនួនគ្រឹះស្ថានសិក្សាគ្រប់កម្រិត*




